# ដើមកំណើតអក្សរខ្មែរ

នៅរដ្ឋអាស៊ីអាគ្នេយ៍បុរាណទាំងដីគោក និងដីកោះ (ខ្មែរ មន ចាម្ប៍ និងជ្វា) យើងពុំឃើញមានតឹកតាងអក្សរកត់ត្រា មុនមានឥទ្ធិពលពីឥណ្ឌានោះឡើយ។ ក្រៅពីឥទ្ធិពលផ្នែកសាសនា របៀបគ្រប់គ្រងរដ្ឋ សិល្បៈ ស្ថាបត្យកម្ម... រដ្ឋទាំងនោះក៏ទទួលឥទ្ធិលអក្សរទាំងស្រុងពីឥណ្ឌាផងដែរ។ អ្នកស្រាវជ្រាវបានរកឃើញថា អក្សរខ្មែរ និងអក្សររដ្ឋអាស៊ីអាគ្នេយ៍បុរាណដទៃទៀតមានប្រភពមកពីឥណ្ឌាភាគខាងត្បូង គឺប្រភេទអក្សរជំមួយឈ្មោះថា "ព្រាហ្មី"នៅសម័យ "បល្លវៈ" (និយមហៅថាអក្សរបល្លវៈ) និង "ចាលុក្យៈ"។


សិលាចារឹកវ៉ូកាញ់

សិលាចារឹកវ័យចំណាស់មួយ ដែលអ្នកស្រាវជ្រាវតែងលើកយកមកពិភាក្សានោះ គឺសិលាចារឹកវ៉ូកាញ់ បច្ចុប្បន្ននៅខេត្តញ៉ាត្រាង ប្រទេសវៀតណាម។ សិលាចារឹកនេះចារក្នុងចន្លោះស.វ.ទី៣-៤គ.ស. សរសេរជាភាសាសំស្ក្រឹត ប្រើអក្សរព្រាហ្មី។ នៅក្នុងបរិបទប្រវត្តិសាស្ត្រកម្ពុជា ក្រោយសិលាចារឹកនេះប្រមាណជា២០០ឆ្នាំ ទើបយើងឃើញមានការចារសិលាចារឹកសំស្ក្រឹត និងបន្ទាប់មកមានសិលាចារឹកភាសាខ្មែរដទៃទៀត ដោយចាប់ផ្ដើមប្រើអក្សរ "បល្លវៈ" ប៉ុន្តែមិនមានចុះកាលបរិច្ឆេទច្បាស់លាស់ឡើយ។ ឯសិលាចារឹកភាសាខ្មែរចាស់ជាងគេដែលមានកាលបរិច្ឆេទច្បាស់លាស់ គឺសិលាចារឹកទួលវត្តគំនូរ K.600 នៅស្រុកអង្គរបុរី ខេត្តតាកែវ ចារនៅឆ្នាំ៦១១នៃគ.ស.។ និយាយជារួមអក្សរខ្មែរដែលប្រើនៅសម័យមុនអង្គរ គឺមានប្រភពមកពីអក្សរឥណ្ឌាភាគខាងត្បូងដែលប្រើតាមលក្ខណៈនិយមបែបខ្មែរ។

បន្ទាប់មក នៅដើមសម័យអង្គរក្នុងរាជ្យព្រះបាទជ័យវម៌្មទី២ និងព្រះបាទជ័យវម៌្មទី៣ អ្នកស្រាវជ្រាវពុំទាន់រកឃើញសិលាចារឹកនៅក្នុងរាជ្យទ្រង់នៅឡើយ។ នៅសម័យនោះទំនងជានៅបន្តប្រើអក្សរសម័យមុនអង្គរដដែល។ លុះមកដល់រាជ្យព្រះបាទយសោវម៌្មទី១ នាចុងស.វ.ទី៩ ដើមស.វ.ទី១០ ទើបគេឃើញមានភស្តុតាងអក្សរបែបថ្មីមួយបែប។ អក្សរនោះហៅថា «កម្ពុជាក្សរ» មានន័យថា «អក្សរកម្ពុជា»។ យើងតែងប្រទះឃើញឃ្លាខ្មែរបុរាណថា

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

”នេះគ្លោកិនេះគិមនិស្រសិរ៊ិនុកម្ពុជាក្សរ” ដែលមានន័យថា “ស្លោកនេះ គឺសរសេរដោយអក្សរកម្ពុជា” នៅខាងចុងផ្ទាំង "ខ" នៃសិលាចារឹកទ្វេអក្សររបស់ព្រះអង្គ ដែលម្ខាងសរសេរជាអក្សរ ”កម្ពុជាក្សរ” និងម្ខាងទៀតសរសេរជាអក្សរ “ទេវនាគរី”[១]។ ក្នុងសិលាចារឹកដដែលក៏មានឃ្លាសំស្រ្កឹតដែលមានសេចក្តីថា “ព្រះរាជាកម្ពុជាដែលមានអានុភាពចាំងចែងបីដូចព្រះសុរិយាដែលមាននេត្រាដូចផ្កាឈូកបានត្រាស់បង្គាប់ឱ្យចារអក្សរនេះ ហៅថា កម្ពុជាក្សរ”។ “កម្ពុជាក្សរ ” បានបង្ហាញពីផ្នត់គំនិតខ្មែរបុរាណឱ្យយល់ច្បាស់ថាអក្សរដែលធ្លាប់ប្រើពីមុនមកជាអក្សរមកពីឥណ្ឌា។ ដូច្នេះហើយទើបមានការកែច្នៃមូលដ្ឋានអក្សរសម័យមុនអង្គរនោះ ឱ្យមានសោភ័ណភាព និងលក្ខណៈបែបខ្មែរនិយម។ ជាពិសេស វាហាក់បីដូចជាបង្ហាញពីវិសាលភាព និងអំណាចរបស់អាណាចក្រខ្មែរនាពេលនោះ ក្រោយការបង្រួមបង្រួមប្រទេសនាដើមសម័យអង្គរផងដែរ។



គំរូសិលាចារឹក កម្ពុជាក្សរ ក្នុងរាជ្យព្រះបាទយសោវរ្ម័ទី១

ចាប់ពីរាជ្យព្រះបាទយសោវរ្ម័ទី១មក យើងពុំឃើញមានសិលាចារឹកនិយាយអំពីឈ្មោះអក្សរខ្មែរទៀតទេ។ ចំណែកឯចលនាកែប្រែទម្រង់រូបរាងអក្សរ គឺអាស្រ័យទៅតាមការនិយមរបស់ព្រះរាជា។ ព្រះរាជាអង្គខ្លះនៅតែបន្តប្រើប្រាស់អក្សរដែលបន្សល់ពីព្រះរាជាអង្គមុន ឯព្រះរាជាអង្គខ្លះទៀតបានកែប្រែទម្រង់អក្សរផ្លូវការក្នុងរាជ្យរបស់ព្រះអង្គដោយផ្អែកលើមូលដ្ឋានអក្សរពីរាជ្យមុនៗដដែល។ ក្រៅពីទម្រង់អក្សរផ្លូវការដែលមានការប្រែប្រួលតាមរាជ្យមហាក្សត្រមួយចំនួននោះ ទម្រង់អក្សរដែលប្រើយ៉ាងសាមញ្ញក្នុងរូបភាពជាអក្សរជ្រៀងហាក់ពុំមានការប្រែប្រួលអ្វីខ្លាំងនោះឡើយ។

[១] សូមអាន អាំង ជូលាន ២០១០ : ៦៨-៧០



សិលាចារឹក K. 362 មានឃ្លា «នេះគ្មោកនេះគិមនិស្រសិរិនុកម្ពុជាក្សរ»



ឃ្លាសិលាចារឹកមានពាក្យ «កម្ពុជាក្សរ» (ប្រភព៖ Khmer Renaissance)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សិលាចារឹកទួលវត្តគំនូរ K.600

ឯកសារយោង

អាំង ជូលាន

២០ ១០ "កម្ពុជាក្សរ" កម្រងអត្ថបទក្នុងបណ្ដាញពត៌មានវប្បធម៌ខ្មែរ

អត្ថបទដោយ៖ ហ៊ុន ឈុនតេង